**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦៨ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលផ្ទៃចឹងជើងឯក ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្ដាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ ខេត្តកណ្ដាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ១៩.៧៣៦ (ដប់ប្រាំបួនម៉ឺនប្រាំពីរយសាមសិបប្រាំមួយ) ម៉ែត្រក្រឡា ពីផ្ទៃបឹងជើងឯកដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ (បច្ចុប្បន្នក្រុងតាខ្មៅ) ខេត្តកណ្ដាល ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដូចមាននិយាមកាចំនួន ០៤ ចំណុចដូចខាងក្រោម៖

| ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|
| A | 491,346.3217 | 1,272,709.1099 |
| B | 491,036.8675 | 1,271,997.4479 |
| C | 490,807.6615 | 1,272,097.2707 |
| D | 491,106.6780 | 1,272,784.9290 |

**មាត្រា ២** : ត្រូវបានប្រគល់ផ្ទៃដីទំហំ ១៩.៧៣៦ (ដប់ប្រាំបួនម៉ឺនប្រាំពីរយសាមសិបប្រាំមួយ) ម៉ែត្រក្រឡា ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ជាកម្មសិទ្ធិជូនរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីសាងសង់ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់។

**មាត្រា ៣** : រាល់ឯកសារពាក់ព័ន្ធនឹងការកាន់កាប់ និងឯកសារទិញលក់កន្លងមក ត្រូវទុកជាមោឃៈ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានស្ថាប័នដែលពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com

# ប្លង់ទីតាំងដីសម្រាប់សាងសង់អាងប្រព្រឹត្តិកម្ម ទឹកកខ្វក់ JICA និងប្រឡាយចេញពីស្ថានីយ៍បូមទឹក បឹងត្របែក ស្ថិតនៅខណ្ឌមានជ័យ រាជធានីភ្នំពេញ




១-និយាមការទីតាំងដីសម្រាប់សាងសង់ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកកខ្វក់តំបន់បឹងជើងឯកគម្រោង JICA

| Piont No. | X | Y |
|---|---|---|
| A | 491,346.3217 | 1,272,709.1099 |
| B | 491,036.8675 | 1,271,997.4479 |
| C | 490,807.6615 | 1,272,097.2707 |
| D | 491,106.6780 | 1,272,784.9290 |

២-និយាមការប្រឡាយទឹកហូរចេញពីស្ថានីយ៍បូមទឹក បឹងត្របែក ទៅអាងស្តុកទឹកតំបន់បឹងជើងឯក

| Piont No. | X | Y |
|---|---|---|
| CB-1 | 491,789.2240 | 1,274,383.6787 |
| CB-2 | 491,869.7400 | 1,274,416.8860 |
| CB-3 | 491,871.7400 | 1,274,351.5600 |
| CB-4 | 491,876.6800 | 1,274,282.8700 |
| CB-5 | 491,893.7500 | 1,274,205.8200 |
| CB-6 | 491,895.9656 | 1,274,156.2320 |
| CB-7 | 491,835.0300 | 1,273,846.6100 |
| CB-8 | 491,804.1600 | 1,273,689.5800 |
| CB-9 | 491,773.3000 | 1,273,532.5500 |
| CB-10 | 491,757.7289 | 1,273,454.6760 |
| CB-11 | 491,665.4619 | 1,273,370.8640 |
| CB-12 | 491,446.1324 | 1,272,697.9047 |
| CB-13 | 491,135.7870 | 1,271,984.1930 |
| CB-14 | 491,065.8408 | 1,271,823.3354 |
| CB-15 | 491,052.1190 | 1,272,032.5222 |
| CB-16 | 491,353.8687 | 1,272,726.4660 |
| CB-17 | 491,365.2749 | 1,272,752.2690 |
| CB-18 | 491,377.1611 | 1,272,793.1289 |
| CB-19 | 491,379.7400 | 1,272,793.7401 |
| CB-20 | 491,439.3500 | 1,272,966.7000 |
| CB-21 | 491,558.5800 | 1,273,312.6299 |
| CB-22 | 491,666.8400 | 1,273,540.8100 |
| CB-23 | 491,687.9000 | 1,273,718.1000 |
| CB-24 | 491,751.1000 | 1,274,249.9800 |

**កំណត់សំគាល់**

- ដីសម្រាប់សាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់JICA
- ព្រំដែនប្រឡាយ
- ព្រំដែនតំរោងស្នើសុំអភិវឌ្ឍន៍
- មហាវិថីអូកញ៉ាតស៊ីសប្បុរសកោជាធិតិហ៊ុន នាង
- ព្រំប្រទល់ខណ្ឌ

| រដ្ឋបាលរាជធានីភ្នំពេញ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានីភ្នំពេញ | មន្ទីរសាធារណការ និង ដឹកជញ្ជូន រាជធានីភ្នំពេញ | រដ្ឋបាលខណ្ឌមានជ័យ |
|---|---|---|---|
| បានឃើញ និង យល់ព្រម | បានឃើញ និង ឯកភាព | បានឃើញ និង ឯកភាព | បានឃើញ និង ឯកភាព |
| ឃួង ស្រេង | សារិន_ទណ្ណា | សាំ ពិសិដ្ឋ | ពេជ្រ_កែវមុនី |

សិក្សាដោយ : ការិយាល័យសាធារណការ

| | នាម និង គោត្តនាម | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|
| គូរដោយ | លោក ជឹម ដា | | ១០-០៧-២០១៨ |
| គូរដោយ | លោក ថេង និស្ស៊ុយ | | ១០-០៧-២០១៨ |
| ពិនិត្យដោយ | លោក ដូ គីមធ្វី | | ១០-០៧-២០១៨ |
| ពិនិត្យដោយ | លោក ទៅ ម៉េងហៃ | | ១០-០៧-២០១៨ |

ឈ្មោះគំរោង :

ប្លង់ទីតាំងដីសម្រាប់សាងសង់អាងប្រព្រឹត្តិកម្មទឹកកខ្វក់ JICA និងប្រឡាយចេញពីស្ថានីយ៍បូមទឹក បឹងត្របែក ស្ថិតនៅខណ្ឌមានជ័យ រាជធានីភ្នំពេញ

| មាត្រដ្ឋាន | ចំនួនសន្លឹក | លេខសន្លឹក |
|---|---|---|
| | | |